ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៧ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារសំរាប់ពិភាក្សាជាមួយតំណាង ស្នងការដ្ឋានជាន់ខ្ពស់របស់សហប្រជាជាតិ ទទួលបន្ទុកជនភៀស ខ្លួនដោះស្រាយជនជាតិព្រៃភ្នំវៀតណាម ដែលកំពុងស្នាក់នៅក្នុងជំរកបណ្តោះអាសន្ននៅទីក្រុងភ្នំពេញ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំ រេ ច

**ប្រការ១:** ត្រូវបានបង្កើតក្រុមការងារសំរាប់ពិភាក្សាជាមួយតំណាងស្នងការដ្ឋានជាន់ខ្ពស់ របស់សហប្រជាជាតិ ទទួលបន្ទុកជនភៀសខ្លួន ដោះស្រាយជនជាតិព្រៃភ្នំវៀតណាម ដែលកំពុងស្នាក់នៅក្នុងជំរកបណ្តោះអាសន្ននៅទីក្រុងភ្នំពេញ ដែលមានសមាសភាពដូចខាងក្រោមនេះ :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ឡុង វិសាលោ** | អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | **ប្រធាន** |
| ២- ឧត្តមសេនីយ៍ឯក | **យូ ស៊ុនឡុង** | អគ្គស្នងការរងនគរបាលជាតិ | **អនុប្រធាន** |
| ៣- ឧត្តមសេនីយ៍ឯក | **សុខ ផល** | ប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ | **សមាជិក** |

| | | |
|---|---|---|
| ៤-លោក | **មាស សុវិរិម** | ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** **សមាជិក** |
| ៥-ឧត្តមសេនីយ៍ត្រី | **គៀត ចំនួចរ៉ិន្ត** | ប្រធាននាយកដ្ឋានជនបរទេស **សមាជិក** |
| ៦-លោក | **កែ ទិសិទ្ធ** | អនុប្រធាននាយកដ្ឋានច្បាប់កុងស៊ុល ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ **សមាជិក** |

**<u>ប្រការ២</u>:** ក្រុមការងារនេះមានភារកិច្ចពិនិត្យពិភាក្សាជាមួយតំណាងស្នងការដ្ឋានជាន់ខ្ពស់ របស់សហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ដោះស្រាយការតាំងទីលំនៅថ្មីនៅប្រទេសទី៣ ឬការធ្វើមាតុភូមិនិវត្តដោយស្ម័គ្រចិត្ត របស់ជនជាតិព្រៃភ្នំវៀតណាម ដែលកំពុងរស់នៅក្នុងជំរកស្នាក់នៅបណ្ដោះអាសន្ននៅទីក្រុងភ្នំពេញ ដើម្បីលើកយោបល់ដាក់ជូនរាជរដ្ឋាភិបាលពិនិត្យសំរេច ។

**<u>ប្រការ៣</u>:** សមាជិកក្រុមការងារត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ ។

**<u>ប្រការ៤</u>:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី និងឯកឧត្តមអស់លោកដែលមានឈ្មោះក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសំរេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០០៤

ជ.នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

ស ខេង

<u>ចម្លងជូន</u>

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

"ដើម្បីជូនជ្រាប"

-ដូចប្រការ៤ "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ